ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរអគ្គិសនីកម្ពុជា
លេខ ៧/២៩ សាក.១៥ អអក

ភ្នំពេញ, ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការពិគ្រោះយោបល់ជាសាធារណៈលើការកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនី ឲ្យអតិថិជនពាណិជ្ជកម្ម ឧស្សាហកម្ម នៅតំបន់ដែលទទួលការផ្គត់ផ្គង់ ចេញពីខ្សែបណ្តាញអគ្គិសនី ២២ kV និង ៣៥ kV របស់អគ្គិសនីកម្ពុជា ប្រភពពីប្រទេសវៀតណាម នៅ ១.ស្វាយរៀង/បាវិត, ២.ពញាក្រែក, ៣.មេមត់, ៤.កំពង់ត្រាច, ៥.ស្នួល, ៦.កែវសីមា និង៧.រតនៈគិរី

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូនសាធារណជនជា **អតិថិជនពាណិជ្ជកម្ម ឧស្សាហកម្ម** នៅតំបន់ដែលទទួលការផ្គត់ផ្គង់ចេញពីខ្សែបណ្តាញអគ្គិសនី ២២ kV និង ៣៥ kV របស់អគ្គិសនីកម្ពុជា ប្រភពប្រទេសវៀតណាម នៅ ១.ស្វាយរៀង/បាវិត, ២.ពញាក្រែក, ៣.មេមត់, ៤.កំពង់ត្រាច, ៥.ស្នួល, ៦.កែវសីមា និង៧.រតនៈគិរី មេត្តាជ្រាបថា អគ្គិសនីវៀតណាម បានតម្លើងថ្លៃលក់ប្រភពអគ្គិសនីឲ្យកម្ពុជា ចំនួន ៧.៥% ថែមទៀតនៅឆ្នាំ២០១៥ នេះ ដែលបានចាប់អនុវត្តពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ។ ជាមួយគ្នានេះ អគ្គិសនីវៀតណាម ពុំបានផ្តល់ប្រភពថាមពលបន្ថែមទៅតាមតម្រូវការដែលកើនឡើងឡើយ ដូច្នេះ អគ្គិសនីកម្ពុជាចាំបាច់ត្រូវរកប្រភពផ្សេង ដើម្បីយកទៅបន្ថែម ហើយប្រភពទាំងនោះ មានតម្លៃថ្លៃជាងការទិញពីអគ្គិសនីវៀតណាម ដោយសារការបញ្ជូនឆ្ងាយ ជាហេតុធ្វើឲ្យអាជីវកម្មនៅតំបន់ទាំង៧ មានការខាតបង់ថែមទៀត ពិបាកនឹងរក្សាឲ្យមាននិរន្តរភាព និងបានធ្វើឲ្យប៉ះពាល់ដល់ស្ថានភាពអាជីវកម្ម។ ដើម្បីរក្សាបាននូវនិរន្តរភាពនៃការផ្គត់ផ្គង់អគ្គិសនី និងអាជីវកម្មនៅតំបន់ទាំង ៧ អគ្គិសនីកម្ពុជាបានស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជា ឲ្យពិនិត្យកំណត់ថ្លៃលក់អគ្គិសនីឲ្យអតិថិជនពាណិជ្ជកម្ម ឧស្សាហកម្ម តាមយន្តការប្រែប្រួលតាមថ្លៃប្រភព បូកថ្លៃសេវាបញ្ជូន និងចែកចាយ (ថ្លៃការគ្រប់គ្រង និងថ្លៃដំណើរការ) ។ សំណើនេះត្រូវបានពិនិត្យ និងពិភាក្សាលម្អិតដោយការវិភាគថ្លៃក្នុងស្ថានភាពបច្ចុប្បន្ន ស្របតាមនីតិវិធីរបស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការវាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី រួចអាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងនឹងធ្វើការសម្រេចកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនីឲ្យអតិថិជនពាណិជ្ជកម្ម ឧស្សាហកម្ម នៅតំបន់ទាំង ៧ ដែលទទួលការផ្គត់ផ្គង់ចេញពីខ្សែបណ្តាញអគ្គិសនី ២២ kV និង ៣៥ kV របស់អគ្គិសនីកម្ពុជា ប្រភពប្រទេសវៀតណាម អនុវត្តតាមយន្តការថ្លៃប្រែប្រួលតាមថ្លៃប្រភព បូកថ្លៃសេវាបញ្ជូន ដូចខាងក្រោម ៖

| ល.រ | ប្រភេទអតិថិជន | ថ្លៃប្រភពទិញពីប្រទេសវៀតណាម* | ថ្លៃបញ្ជូន និងចែកចាយ | អត្រាថ្លៃលក់ |
|---|---|---|---|---|
| ១ | ទិញលើតង់ស្យុងមធ្យម | 0.1114 US$/kWh | **0.039 US$/kWh** | 0.1504 US$/kWh |
| ២ | ទិញលើតង់ស្យុងទាប | 0.1114 US$/kWh | **0.045 US$/kWh** | 0.1564 US$/kWh |

*ថ្លៃប្រភពទិញពីប្រទេសវៀតណាម សម្រាប់ឆ្នាំ២០១៥ ស្មើ 0.1114 US$/kWh រួមបញ្ចូលពន្ធនាំចូល ៧% និង ពន្ធតម្លៃបន្ថែម VAT ១០%។



**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

អនុវត្តតាមនីតិវិធីកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសូមដាក់ "ឯកសារកែសម្រួលថ្លៃលក់អគ្គិសនី តាមយន្តការប្រែប្រួលតាមថ្លៃប្រភព បូកថ្លៃសេវាបញ្ជូន និងចែកចាយ" នេះ ពិគ្រោះយោបល់ជាសាធារណៈ ជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ទាំងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ទាំងអាជ្ញាធរមូលដ្ឋាន និងទាំងសាធារណៈជនអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងតំបន់ចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជាទាំង ៧ ខាងលើ ចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥។ ក្រោយថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥** "ឯកសារកែសម្រួលថ្លៃលក់អគ្គិសនី តាមយន្តការប្រែប្រួលតាមថ្លៃប្រភព បូកថ្លៃសេវាបញ្ជូន និងចែកចាយ" នេះ នឹងត្រូវចាត់ទុកថា បានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជាអាចធ្វើការពិនិត្យ និងអនុម័តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះ ទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

ដើម្បីឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា អាចអនុវត្តការកែសម្រួលថ្លៃលក់អគ្គិសនី ស្របទៅតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសំណូមពរសុំឲ្យការផ្តល់យោបល់មកឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាមានមូលដ្ឋានសំអាងគ្រប់គ្រាន់ អាចអនុវត្តបានទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យ លេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ បាន ហើយសូមឲ្យការផ្តល់យោបល់នេះ រក្សានូវតុល្យភាពឲ្យបានយុត្តិធម៌ រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់អគ្គិសនីផង និងអ្នកធ្វើសេវាកម្មផង។ ឯកសារគណនាបញ្ជីថ្លៃលក់អគ្គិសនី ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យ លេខ៥៤.អនក្រ.បក មានតម្កល់ទុកនៅ ------------------------------------------------------------------------- សម្រាប់អ្នកពាក់ព័ន្ធមានអាជ្ញាធរមូលដ្ឋាន និងទាំងសាធារណៈជនអ្នកប្រើប្រាស់អគ្គិសនីទាំងអស់ ដែលមានចំណាប់អារម្មណ៍ ពិនិត្យដោយសេរី នៅគ្រប់ពេលម៉ោងធ្វើការ។

អាស្រ័យហេតុនេះ សូមសាធារណៈជនទាំងអស់ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់យោបល់ដល់អាជ្ញាធរអគ្គិសនីកម្ពុជា លើ "ឯកសារបញ្ជីថ្លៃលក់ តាមយន្តការប្រែប្រួលតាមថ្លៃប្រភព បូកថ្លៃសេវាបញ្ជូន និងចែកចាយ" ថ្មីនេះ មេត្តាជ្រាបជាពត៌មាន។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ទី នរិន្ទ**



**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh